# ជនជាតិដើមភាគតិចកួយខេត្តព្រះវិហារ ជិត១០០នាក់ធ្វើពិធីដាក់បណ្តាសាអ្នករំលោភយកដីពួកគាត់



*ពលរដ្ឋជនជាតិភាគតិចកួយជិត ១០០នាក់ នាំគ្នាធ្វើពិធីដាក់បណ្តាសាអ្នករំលោភយកដីពួកគាត់ នៅភូមិប្រើសក្អក ឃុំម្លូព្រៃ ស្រុកឆែប ខេត្តព្រះវិហារ កាលពីថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០២៤។*

ជនជាតិដើមភាគតិចកួយ នៅស្រុកឆែប ខេត្តព្រះវិហារ ជិត១០០នាក់ធ្វើពិធីដាក់បណ្តាសាដល់អ្នកដែលរំលោភយកដី និងឈូសឆាយដំណាំពួកគាត់ជាច្រើនហិកតារ។ មន្ត្រីសង្គមស៊ីវិលថា ការធ្វើពិធី គឺជាសិទ្ធិសេរីភាពរបស់ពួកគាត់ ហើយអាជ្ញាធរគួរតែយកកង្វល់ទាំងនោះមកដោះស្រាយឱ្យបានឆាប់។

ប្រជាសហគមន៍ជនជាតិដើមភាគតិចកួយ មកពីភូមិប្រើសក្អក និងភូមិបុស្ស ឃុំម្លូព្រៃ ជិត១០០នាក់ បានធ្វើពិធីដាក់បណ្តាសា ដល់អ្នកមានលុយមានអំណាចដែលបានរំលោភយកដីធ្លីពួកគាត់ ជាង១០ឆ្នាំមកនេះ។ ពួកគាត់ថា ពិធីនេះ ធ្វើ

ដើម្បីផ្ញើសារ និងទាមទារឱ្យនាយករដ្ឋមន្ត្រី ហ៊ុន ម៉ាណែត ពន្លឿនការដោះស្រាយវិវាទដីធ្លី នេះឱ្យបានឆាប់។

ការធ្វើពិធីដាក់បណ្ដាសារបស់ជនជាតិដើមភាគតិចកួយ ធ្វើឡើងនៅថ្ងៃទី១ ខែកុម្ភៈ នៅលើដីដែលក្រុមហ៊ុន បានឈូសឆាយដំណាំរាប់ពាន់ហិកតាររបស់ពួកគាត់ចោល កាលពីដើមខែមករា កន្លងទៅ។ នៅក្នុងពិធីនេះ មានសែនក្បាលជ្រូក និងទៀន ធូប ជាដើម តាមបែបប្រពៃណីរបស់ពួកគាត់។តំណាងសហគមន៍ជនជាតិភាគតិចកួយ នៅភូមិប្រើសក្អក លោក សឿន ថា ប្រាប់វិទ្យុអាស៊ីសេរីនៅថ្ងៃទី២ ខែកុម្ភៈ ថា ការណ៍ដែលពួកគាត់ធ្វើពិធីដាក់បណ្ដាសានេះ ដោយសារតែពលរដ្ឋរងភាពអយុត្តិធម៌ជាបន្តបន្ទាប់ពីសំណាកក្រុមហ៊ុនចិន។ ជាក់ស្ដែង លោកថា កាលពីដើមខែមករានេះ ដំណាំដំឡូងរបស់ពួកគាត់ជាច្រើនហិកតារ ត្រូវបានក្រុមហ៊ុនឈូសឆាយ ចំណែកពួកគាត់ត្រូវគំរាមសម្លាប់ និងជេរប្រមាថគ្រប់រូបភាព។

លោក សឿន ថា៖ «*ស្នើឱ្យពួកគាត់នឹងមេត្តាកាត់ឆ្វៃលដីជូនមកពលរដ្ឋរបស់យើងវិញ ដើម្បីឱ្យពួកគាត់ បានអាស្រ័យផល។ ពីព្រោះហាមពលរដ្ឋមិនឱ្យចូលទៅអាស្រ័យផល ប៉ុន្តែហាមតែពលរដ្ឋយើងដែលរស់នៅជាម្ចាស់ទឹកម្ចាស់ដីដែលនៅតំបន់នោះ ដោយឡែក អ្នកមានអំណាចមានលុយមួយចំនួន ដោយចូលធ្វើបាន ហើយមានការអះអាងថា មានច្បាប់ការពារទៅវិញ*»។

អភិបាលរងខេត្តព្រះវិហារ លោក ណុប វុទ្ធី ប្រាប់វិទ្យុអាស៊ីសេរីនៅថ្ងៃទី២ ខែកុម្ភៈនេះ ថា ការធ្វើពិធីដាក់បណ្ដាសា ឬការទាមទាររកដំណោះស្រាយ រឿងវិវាទដីធ្លីនេះ គឺជាសិទ្ធិរបស់ពួកគាត់ តែយ៉ាងណា អាជ្ញាធរពាក់ព័ន្ធកំពុងតែព្យាយាមដំណោះស្រាយ ជាបណ្ដើរៗហើយ។

លោក ណុប វុទ្ធី៖ «*បើចង់ធ្វើ[ពិធីដាក់បណ្ដាសា] នេះជាសិទ្ធិរបស់គាត់ យើងអត់មានការហាមឃាត់ ពួកគាត់បាននោះទេ។ ប៉ុន្តែនីតិវិធីក្នុងការធ្វើ[ដោះស្រាយដីធ្លី*

*] យើងត្រូវចំណាយពេលវេលាយូរដើម្បីធ្វើការងារ ដើម្បីប្រមូលចងក្រងឯកសារព័ត៌មានទាំងអស់ហ្នឹងមុន យើងធ្វើការវិនិច្ឆ័យ។ អាជ្ញាធរយើងកំពុងធ្វើការដោះស្រាយ ព្រោះយើងមានគណៈកម្មការរបស់យើង*»។

ទោះជាអះអាងបែបនេះក្តី អភិបាលរងខេត្តរូបនេះ កាលពីថ្ងៃទី២៦ ខែមករា លោកបានលើកឡើងនៅក្នុងសន្និសីទសារព័ត៌មាន នៅក្នុងខេត្តរបស់ខ្លួន ដោយព្រមានឱ្យពលរដ្ឋទាំងអស់ បញ្ឈប់ការបង្កបង្កើនផលលើដីនោះទៀត បើពុំចង់មានទោសទណ្ឌតាមផ្លូវច្បាប់ ។ លោកបញ្ជាក់ថា ដីដែលពលរដ្ឋអាស្រ័យផលនោះ គឺជាដីរដ្ឋដែលរដ្ឋាភិបាល បានវិនិយោគឱ្យក្រុមហ៊ុន។

ទាក់ទិនរឿងនេះអ្នកសម្របសម្រួលគម្រោងធុរកិច្ច និងសិទ្ធិមនុស្សរបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា លោក វណ្ណ សុផាត សង្កេតឃើញថា វិវាទដីធ្លីរបស់ពលរដ្ឋជនជាតិដើមភាគតិចកួយ នៅខេត្តព្រះវិហារនេះ បានអូសបន្លាយជាង ១០ឆ្នាំហើយ។ លោកថា ករណីនេះ អាជ្ញាធរពាក់ព័ន្ធពុំមានឆន្ទៈដោះស្រាយពិតប្រាកដនោះទេ ជាក់ស្តែងអាជ្ញាធរតែងតែចាត់ទុកពលរដ្ឋថា ជនល្មើស។

លោក វណ្ណ សុផាត៖ «*រហូតមកដល់បច្ចុប្បន្នទាំងអាជ្ញាធរ ទាំងក្រុមហ៊ុន ទាំងប្រព័ន្ធ យុត្តិធម៌ផងដែរ នៅតែប្រើប្រាស់ប្រព័ន្ធយុត្តិធម៌ ប្រព័ន្ធតុលាការ ដើម្បីដាក់សម្ពាធទៅលើប្រជាពលរដ្ឋ ពេលគាត់អស់ដី នឹងមានការតវ៉ា។ អ៊ីចឹងទៅ ចោទពួកគាត់ពីបទព្រហ្មទណ្ឌ បទប្រើអំពើហិង្សា។ ដូច្នេះ អាជ្ញាធរ និងស្ថាប័នពាក់ព័ន្ធជាពិសេសរដ្ឋ ត្រូវតែពិនិត្យទៅលើបញ្ហានេះឱ្យបានច្បាស់លាស់ ហើយបើមានយកដីពួកគាត់ត្រូវអនុវត្តតាមនីតិវិធីច្បាប់*»។

ជនជាតិដើមភាគតិចកួយ មានវិវាទដីធ្លី ដ៏រ៉ាំរ៉ៃជាង១០ឆ្នាំ ជាមួយនឹង ក្រុមហ៊ុនស្ករអំពៅចិនឈ្មោះ ហេងហ្វូ គ្រុប ស៊ូហ្គើរ អីនដាស្ទ្រី (Hengfu Group Sugar Industry) ។ មកដល់ពេលនេះនៅមានប្រជាពលរដ្ឋជាង ៧០០គ្រួសារ នៅស្រុកឆែប ស្រុក

ត្បែងមានជ័យ និងស្រុកជ័យសែន កំពុងរងផលប៉ះពាល់ដោយមានជីវភាពដុនដាបកាន់តែខ្លាំង ក្រោយពីរដ្ឋាភិបាលបានផ្តល់សិទ្ធិវិនិយោគឱ្យក្រុមហ៊ុន កាលពីឆ្នាំ ២០១១ លើផ្ទៃដីជាង ៤ម៉ឺនហិកតារ (៤២.០០០)។

ជនជាតិដើមភាគតិចលើកឡើងថា ចាប់តាំងពីមានវិវាទជាមួយក្រុមហ៊ុនចិនមក ការបង្កបង្កើនផល នៅលើដីរបស់ពួកគាត់ទាំងប្រថុយប្រថាន ព្រោះប្រឈមនឹងការគំរាមកំហែងពីសំណាក់ក្រុមហ៊ុន ចំណែករដូវប្រាំង ដំណាំដំឡូងរាប់ពាន់ហិកតារ ប្រឈមការដុតចោល។ ទោះបែបនេះក្តី ពួកគាត់ថា នៅតែប្រកាន់ជំហរទាមទារ ហើយនឹងដាក់ញត្តិ ដល់រដ្ឋាភិបាល ឱ្យជួយអន្តរាគមន៍ក្នុងពេលឆាប់ៗ៕